# អត្រាអាំងស៊ីដង់នៃមេរោគអេដស៍ក្នុងចំណោមក្រុមប្រជាជនគោលដៅដែលត្រូវបានអង្កេត ពីឆ្នាំ ១៩៩៩ ដល់ ២០០២

ដកស្រង់ចេញពីផ្នែកមួយនៃបរិមាធិប្បាយ សំរាប់សញ្ញាប័ត្របណ្ឌិតរបស់

លោក សាផុន វឌ្ឍនះ នៅសកលវិទ្យាល័យកាលីហ្វ័នីញ៉ា លូសអង់ជីលេស សហរដ្ឋអាមេរិក

ធ្វើនៅសណ្ឋាគារ MICASA ក្រុងភ្នំពេញ

ថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០០៤

## សេចក្ដីថ្លែងអំណរគុណ


- លោកសាស្ត្រាចារ្យ Roger Detels
- លោក និង លោកស្រីសាស្ត្រាចារ្យ Babara Visscher, Abdelmonem A. Afifi, John Fahey and Eric L. Hurwitz
- លោក វេជ្ជ Parekh Barath និងលោកស្រី Trudy Dobbs
- លោក វេជ្ជ Anthony Butch, លោក វេជ្ជ Najib Aziz និងលោក Carlos Garibay
- លោក វេជ្ជ មាន ឈី វុន លោក វេជ្ជ ទា ផលា លោក វេជ្ជ ហោ ប៊ុនឡេង និង លោកស្រីវេជ្ជ សេង ស៊ុតវណ្ណថា
- កម្មវិធី ហ្វ័រហ្គាទី អន្តរជាតិ អង្គការ CDC-GAP នៅកម្ពុជា និង អង្គការ UNAIDS
- មជ្ឈមណ្ឌលជាតិប្រយុទនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ និង ក្រសួងសុខាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- សហសេវិក ដែលធ្វើការនៅ មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ

# មាតិកាសំខាន់ៗដែលនឹងលើកយកមកបង្ហាញ

១. មូលហេតុដែលនាំអោយធ្វើការសិក្សាស្រាវជ្រាវនេះ

២. គោលបំណងចំបង និង គោលបំណងជាក់លាក់ របស់ការសិក្សាស្រាវជ្រាវ

៣. ការពិនិត្យឡើងវិញលើរាល់ការស្រាវជ្រាវដែលបានធ្វើកន្លងមក

៤. វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ

៥. លទ្ធផល

៦. ពិភាក្សា

៧.ការប្រើប្រាស់លទ្ធផល និង អនុសាសន៍

៨. សេចក្តីសន្និដ្ឋាន

## ចំនុចសំខាន់ៗគួរអោយកត់សំគាល់ក្នុងប្រវត្តិរាលដាលមេរោគអេដស៍នៅកម្ពុជា

- ១៩៩១: របាយការណ៏អ្នកផ្ទុកមេរោគអេដស៏ដំបូង
- ១៩៩៣: របាយការណ៏អ្នកជំងឺអេដស៏ដំបូង
- ១៩៩៥: ការអង្កេតតាមដានរកមេរោគអេដស៏លើកដំបូង (៨លើក)
- ១៩៩៦: ការអង្កេតតាមដានរកជំងឺកាមរោគលើកដំបូង (២លើក)
- ១៩៩៧: ការអង្កេតតាមដានការប្រព្រឹត្តផ្លូវភេទលើកដំបូង (៦លើក)

## ការប្រែប្រួលការរាលដាលនៃមេរោគអេដស៍ ពីឆ្នាំ ១៩៩៥- ២០០២

តើមានការប្រែប្រួលអត្រាប្រេវ៉ាឡង់នៃមេរោគអេដស៍យ៉ាងណាដែរក្នុងកំឡុងពេលពីឆ្នាំ ១៩៩៥- ២០០២?

## ខេត្ត និង ក្រុមប្រជាជនគោលដៅដែលចូលរួមក្នុងការ អង្កេតតាមដានអត្រាប្រេវ៉ាឡង់មេរោគអេដស៍

| | HSS I 1995 | HSS II 1996 | HSS III 1997 | HSS IV 1998 | HSS V 1999 | HSS VI 2000 | HSS VII 2002 |
|---|---|---|---|---|---|---|---|
| ចំនួនខេត្ត | 9 | 18 | 22 | 19 | 20 | 21 | 20 |
| នារីរកស៊ីផ្លូវភេទផ្ទាល់ | X | X | X | X | X | X | X |
| នារីរកស៊ីផ្លូវភេទមិនផ្ទាល់ | X | | | X | X | X | X |
| ប៉ូលីស | X | X | X | X | X | X | X |
| ស្ត្រីមានផ្ទៃពោះ | X | X | X | | X | X | X |

## អត្រាប្រេវ៉ាឡង់មេរោគអេដស៍ក្នុងចំណោម នារីរកស៊ីផ្លូវភេទដោយផ្ទាល់ ទៅតាមក្រុមអាយុ ពីឆ្នាំ ១៩៩៨ ដល់ ២០០២




Source: HSS 2002 dissemination workshop. National Center for HIV/AIDS, Dermatology and STDs

## អត្រាប្រេវ៉ាឡង់មេរោគអេដស៍ក្នុងចំណោម នារីរកស៊ីផ្លូវភេទមិនផ្ទាល់ ទៅតាមក្រុមអាយុ ពីឆ្នាំ ១៩៩៨ ដល់ ២០០២




Source: HSS 2002 dissemination workshop. National Center for HIV/AIDS, Dermatology and STDs

## អត្រាប្រេវ៉ាឡង់មេរោគអេដស៍ក្នុងចំណោមប៉ូលីសនៅទីរួមខេត្ត
## ពីឆ្នាំ ១៩៩៨ ដល់ ២០០២




Source: HSS 2002 dissemination workshop. National Center for HIV/AIDS, Dermatology and STDs

## អត្រាប្រេវ៉ាឡង់មេរោគអេដស៍ក្នុងចំណោមស្ត្រីមានផ្ទៃពោះ
## ពីឆ្នាំ ១៩៩៧ ដល់ ២០០២




*Adjusted prevalence calculated by smoothing provincial level prevalence and aggregating into national estimate

Source: HSS 2002 dissemination workshop. National Center for HIV/AIDS, Dermatology and STDs

## អត្រាប្រេវ៉ាឡង់មេរោគអេដស៍ក្នុងចំណោមមនុស្សពេញវ័យ អាយុពី ១៥ ដល់ ៤៩ ឆ្នាំ នៅកម្ពុជា




Source: HSS 2002 dissemination workshop. National Center for HIV/AIDS, Dermatology and STDs

## ហេតុអ្វីធ្វើការសិក្សាស្រាវជ្រាវនេះ?

- ១២ឆ្នាំ បន្ទាប់ពីមានរបាយការណ៍ករណីផ្ទុកមេរោគអេដស៍ដំបូង នៅកម្ពុជា អង្គការ UNAIDS បានទទួលស្គាល់ថា ការរាលដាលនៃមេរោគអេដស៍នៅកម្ពុជាបានឈានដល់ដំណាក់កាលមានលំនឹងហើយ ។ អត្រាប្រេវ៉ាឡង់មេរោគអេដស៍ក្នុងចំណោមស្ត្រីមានផ្ទៃពោះនៅក្នុងទីប្រជុំជនសំខាន់ៗបានធ្លាក់ចុះបន្តិចពី ៣.២% នៅឆ្នាំ ១៩៩៦ មក ២.៨% នៅឆ្នាំ ២00២ ហើយអត្រាប្រេវ៉ាឡង់មេរោគអេដស៍ក្នុងចំណោមនារីរកស៊ីផ្លូវភេទបានធ្លាក់ចុះពី ៤២.% នៅឆ្នាំ ១៩៩៨ មក ២៩% នៅឆ្នាំ ២00២ ។
- មានសំនួរលើកឡើងអំពី ទំនាក់ទំនងនៃការធ្លាក់ចុះអត្រាប្រេវ៉ាឡង់ និង អត្រា អាំងស៊ីដង់ និង អត្រាមរណៈភាពដោយសារជំងឺអេដស៍
- ឈាមដែលប្រមូលទាំងអស់នៅក្នុងការអង្កេតតាមដានមេរោគអេដស៍ ពីឆ្នាំ ១៩៩៩ ដល់ ឆ្នាំ ២00២ បានរក្សាទុកក្នុងទូទឹកកក
- យុទ្ធសាស្ត្រថ្មីសំរាប់ធ្វើតេស្តរកកណើឆ្លងមេរោគអេដស៍ថ្មីៗត្រូវបានបង្កើតឡើង

## គោលបំណងចំបង

ពន្យល់នូវឌីណាមិកនៃការរាលដាលមេរោគអេដស៍ នៅប្រទេសកម្ពុជា នៅក្នុងចំណោម ក្រុមប្រជាជនគោលដៅ ផ្សេងៗ ដែលត្រូវបានអង្កេតតាមដាន ដោយផ្ដោតការពិនិត្យ ទៅលើអត្រាអាំងស៊ីដង់

## គោលបំណងជាក់លាក់

- ធ្វើការប៉ាន់ស្មាន អត្រាប្រេវ៉ាឡង់មេរោគអេដស៍ដែលទើបឆ្លងថ្មីៗ ក្នុងចំណោម ក្រុមប្រជាជនគោលដៅផ្សេងៗដែលត្រូវបាន អង្កេតតាមដាន ដោយប្រើបច្ចេកទេសថ្មីឈ្មោះ IgG BED-CEIA
- ធ្វើការប៉ាន់ស្មាន អត្រាអាំងស៊ីដង់មេរោគអេដស៍ ចេញពីអត្រាប្រេវ៉ាឡង់ មេរោគអេដស៍ដែលទើបឆ្លងថ្មីៗ ក្នុងចំណោមក្រុមប្រជាជនគោលដៅ ផ្សេងៗដែលត្រូវបានអង្កេតតាមដាន

## វិធីសាស្ត្រធ្វើការប៉ាន់ស្មាន អត្រាអាំងស៊ីដង់មេរោគអេដស៍

- វិធីសាស្ត្រដោយផ្ទាល់
  - ប្រើវិធី open or dynamic cohort
  - ប្រើ វិធី closed or fixed cohort method
- វិធីសាស្ត្រមិនផ្ទាល់
  - ប្រើ ទិន្នន័យអត្រាប្រេវ៉ាឡង់ដើម្បីប៉ាន់ស្មាន អត្រាអាំងស៊ីដង់
  - ធ្វើការគណនាត្រលប់ក្រោយ ដោយប្រើប្រាស់តួលេខរបាយការណ៍ ករណីអ្នកជំងឺអេដស៍ដើម្បីគណនាអត្រាឆ្លងមេរោគអេដស៍ដោយ ផ្អែកលើប្រវត្តនៃការឆ្លង
  - ប្រើប្រាស់វិធីសាស្ត្រ **birth cohort** ដើម្បីប៉ានស្មានអត្រាអាំងស៊ិដង ដោយប្រើ **slopes of trend lines** ចេញពីគំរូដដែលៗនៃ **birth cohorts**

## តើប្រើទិន្នន័យអត្រាបេវ៉ាឡង់យ៉ាងណាដើម្បីធ្វើការប៉ានស្មាន អត្រាអាំងស៊ីដង់

- **p24 antigenemia** របស់មនុស្សដែលមិនទាន់មាន **seroconverted:** ធ្វើតេស្ត **HIV p24 antigen** ឬ រួមបញ្ចូលការធ្វើតេស្ត **HIV p24 antigen** និង **reverse transcriptase-polymerase chain reaction (RT-PCR) –** តេស្តនេះត្រូវធ្វើលើសំនាកអវិជ្ជមាន
- យុទ្ធសាស្ត្រធ្វើតេស្ត **sensitive/less sensitive serologic,** តេស្តនេះត្រូវធ្វើលើសំនាកវិជ្ជមាន

## គំនូសបន្ទាញពីការផ្លាស់ប្តូរប៉ារ៉ាម៉ែតផ្សេងៗដែលកំនត់ ដំណាក់កាលដំបូង និង ដំណាក់កាលចុងក្រោយ នៃការឆ្លងមេរោគអេដស៍




## វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ




## ប្រភពទិន្នន័យ

- ការសិក្សាស្រាវជ្រាវនេះបានប្រើប្រាស់សំនាករបស់ក្រុមប្រជាជនគោលដៅដែលបានប្រមូលទុកចាប់តាំងពីឆ្នាំ ១៩៩៩ ដល់ ឆ្នាំ ២០០២
- មានប្រជាជនគោលដៅចំនួន ៤ ក្រុមដែលបានជ្រើសរើសចូលក្នុងការសិក្សានេះ
  - ស្ត្រីមានផ្ទៃពោះដែលមកពិនិត្យសុខភាពនៅ គ្លីនិកពិនិត្យស្ត្រីមានផ្ទៃពោះ
  - នរគរបាលជាតិ
  - ស្ត្រីរកស៊ីផ្លូវភេទដោយផ្ទាល់
  - នារីរកស៊ីផ្លូវភេទមិនផ្ទាល់

## ចំនួនមនុស្សដែលត្រូវចូលរួមការសិក្សា និង វិធីជ្រើសរើស

- ចំនួនមនុស្សដែលត្រូវចូលរួមការសិក្សា និង វិធីជ្រើសរើសបានរៀបចំឡើងដោយមជ្ឈមណ្ឌល
- ចំនួនមនុស្សដែលចូលរួមមានដូចតទៅ:

  - ស្ត្រីមានផ្ទៃពោះ : ៣០០ មកពីទីរួមខេត្ត និង ៣០០ មកពីបណ្តាលស្រុក ក្រៅពីទីរួមខេត្ត

  - ប៉ូលីស និងស្ត្រីរកស៊ីផ្លូវភេទដោយមិនផ្ទាល់ : ៣០០ នៅកន្លែងណាដែលអត្រាប្រេវ៉ាឡង់ដែលយើងដឹងចុងក្រោយបង្អស់ ៥% រឺតិចជាង ហើយ ១០០-១៥០ នៅបណ្តាកន្លែងណាដែលមានអត្រាប្រេវ៉ាឡង់ដែលយើងដឹងចុងក្រោយបង្អស់លើសពី ៥%

  - ស្ត្រីរកស៊ីផ្លូវភេទដោលផ្ទាល់ : ១០០-១៥០
- វិធីសាស្ត្រជ្រើសរើស :

  - ស្ត្រីមានផ្ទៃពោះ : ជ្រើសរើសបន្តបន្ទាប់

  - ស្ត្រីរកស៊ីផ្លូវភេទដោលផ្ទាល់ និងស្ត្រីរកស៊ីផ្លូវភេទមិនផ្ទាល់ : ជ្រើសរើសជាចង្កោម រឺជ្រើសរើសដោយយកទាំងអស់

  - ប៉ូលីស : ជ្រើសរើសជាចង្កោម)

## ការប្រមូលសំនាក

- បូមឈាម ៥ម.ល ពីអ្នកចូលរួមម្នាក់ៗដាក់ក្នុងបំពង់សំរាប់ទុកឈាម
- សំរាំងយកសេរ៉ូម ២ម.ល ពីឈាមនោះហើយរក្សាទុកក្នុងកូនបំពង់ **Cryotube**
- សំនាកទាំងអស់ត្រូវប្រមូលផ្តុំហើយធ្វើតេស្ត ហើយត្រូវបានរក្សាទុកនៅក្នុងសីតុណ្ហភាព-២០ C នៅមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៏ សើស្បែក និងកាមរោគ
- រាល់សំនាកដែលមានផ្ទុកមេរោគអេដស៏ ទាំងអស់ត្រូវបានដឹកជញ្ជូនទៅសកលវិទ្យាល័យកាលីហ្វូនីញ៉ា លូសអង់ជឺលេស ដើម្បីធ្វើតេស្ត BED-CEIA

## វិធីសាស្ត្រនៃការធ្វើតេស្ត




## ការប៉ាន់ស្មានអត្រាអង់ស៊ីដង់ពីអត្រាប្រេវ៉ាឡង់នៃអ្នកឆ្លងថ្មី

$$P = I \times D$$

**P**revalent cases = **I**ncident cases x **D**uration in disease state

ចំនួនករណីប្រេវ៉ាឡង់ = ចំនួនករណីអាំងស៊ីដង់ x រយៈពេលដែលមានជំងឺ

# លទ្ធផល

## តំបន់ក្នុងប្រទេសកម្ពុជា

- តំបន់ភាគខាងលិច មានព្រំប្រទល់ជាប់ជាមួយប្រទេសថៃមានខេត្តចំនួន៨ គឺ ខេត្តបន្ទាយមានជ័យ បាត់ដំបង កោះកុង ប៉ៃលិន ពោធិសាត់ ព្រះវិហារ ឧត្ដមានជ័យ និង ក្រុងព្រះសីហនុ
- តំបន់ភាគខាងកើត ព្រំប្រទល់ជាមួយវៀតណាម មានខេត្តចំនួន១០ គឺ ខេត្តកំពង់ចាម កំពត ក្រុងកែប ខេត្តក្រចេះ ព្រៃវែង រតនះគីរី មណ្ឌលគីរី ស្ទឹងត្រែង ខេត្តស្វាយរៀង និង តាកែវ
- តំបន់កណ្ដាល មាន ៦ខេត្ត : ខេត្តកំពង់ឆ្នាំង កំពង់ស្ពឺ កំពង់ធំ កណ្ដាល រាជធានីភ្នំពេញ និង ខេត្តសៀមរាប

## ភាគរយនៃការប្រកែកមិនចូលរួមការអង្កេត(អប្បរមា-អតិបរមា) ក្នុងចំណោមប្រជាជនគោលដៅ

| | 1999 | 2000 | 2002 |
|---|---|---|---|
| ស្ត្រីមានផ្ទៃពោះ | 6.70(0-23.45) | NA | 1.9 (0-18.5) |
| ស្ត្រីរកស៊ីផ្លូវភេទផ្ទាល់ | 21.50(0-46.99) | 4.9 (0-18.0) | 4.8 (0-16.2) |
| ស្ត្រីរកស៊ីផ្លូវភេទមិនផ្ទាល់ | 35.70(0-58.00) | 11.9 (0-32.3) | 11.6 (0-37.7) |
| ប៉ូលីស | 24.30(0-54.20) | 8.6 (0-58.0) | 14.6 (0-57.8) |

## ភាគរយនៃលទ្ធផលមិនត្រឹមត្រូវរបស់សំណាកវិជ្ជមាន

| Year | Group | Specimen transferred to UCLA | HIV + after two different ELISA at UCLA | False positive |
|---|---|---|---|---|
| 1999 | ANC | 119 | 94 | 21.01% |
| | CSW | 730 | 678 | 7.12% |
| | IDSW | 228 | 193 | 15.35% |
| | POL | 189 | 148 | 21.69% |
| 2000 | ANC | 140 | 106 | 24.29% |
| | CSW | 649 | 622 | 4.16% |
| | IDSW | 276 | 245 | 11.23% |
| | POL | 143 | 128 | 10.49% |
| 2002 | ANC | 239 | 178 | 25.52% |
| | CSW | 588 | 524 | 10.88% |
| | IDSW | 168 | 148 | 11.90% |
| | POL | 130 | 107 | 17.69% |
| | Overall | 3599 | 3171 | 11.89% |

## លក្ខណៈប្រជាសាស្ត្រនៃស្ត្រីមានផ្ទៃពោះ
## ដែលចូលរួមក្នុងការសិក្សាស្រាវជ្រាវ ពីឆ្នាំ ១៩៩៩ ដល់ ២០០២

| | 1999 | | 2000 | | 2002 | |
|---|---|---|---|---|---|---|
| Characteristics | Frequency | % | Frequency | % | Frequency | % |
| Age | | | | | | |
| 14-19 years | 531 | 10.42 | 559 | 9.35 | 1,618 | 18.53 |
| 20-29 years | 2,854 | 55.99 | 3,294 | 55.12 | 4,494 | 51.45 |
| 30-39 years | 1,490 | 29.23 | 1,779 | 29.77 | 2,272 | 26.01 |
| 40-49 years | 222 | 4.36 | 344 | 5.76 | 350 | 4.01 |
| Schooling | | | | | | |
| <=4 years | 1,842 | 36.14 | 2,179 | 36.77 | 3,687 | 42.2 |
| 5-8 years | 2,057 | 40.36 | 2,734 | 46.14 | 3,660 | 41.9 |
| 9-12 years | 733 | 14.38 | 978 | 16.5 | 1,347 | 15.42 |
| >12 years | 465 | 9.12 | 35 | 0.59 | 42 | 0.48 |
| Married | 5,097 | 100 | 5,976 | 100 | 8,720 | 99.82 |
| Urban | 3,238 | 63.53 | 3,546 | 59.34 | 4,928 | 56.41 |

## លក្ខណៈប្រជាសាស្ត្រនៃស្ត្រីរកស៊ីផ្លូវភេទផ្ទាល់
## ដែលចូលរួមក្នុងការសិក្សាស្រាវជ្រាវ ពីឆ្នាំ ១៩៩៩ ដល់ ២០០២

| | 1999 | | 2000 | | 2002 | |
|---|---|---|---|---|---|---|
| Characteristics | Frequency | % | Frequency | % | Frequency | % |
| Age | | | | | | |
| 14-19 years | 607 | 27.9 | 430 | 21.11 | 406 | 19.72 |
| 20-29 years | 1,411 | 64.84 | 1,450 | 71.18 | 1,505 | 73.09 |
| 30-39 years | 145 | 6.66 | 153 | 7.51 | 145 | 7.04 |
| 40-49 years | 11 | 0.51 | 4 | 0.2 | 3 | 0.15 |
| Schooling | | | | | | |
| <=4 years | 1,712 | 78.68 | 1,512 | 74.68 | 1,545 | 75.4 |
| 5-8 years | 422 | 19.39 | 472 | 23.16 | 457 | 22.2 |
| 9-12 years | 39 | 1.79 | 44 | 2.16 | 57 | 2.77 |
| >12 years | 3 | 0.14 | 0 | 0 | 0 | 0 |
| Married | 447 | 20.54 | 658 | 32.29 | 556 | 27 |
| Urban | - | - | - | - | - | - |

## លក្ខណៈប្រជាសាស្ត្រនៃស្ត្រីរកស៊ីផ្លូវភេទមិនផ្ទាល់
## ដែលចូលរួមក្នុងការសិក្សាស្រាវជ្រាវ ពីឆ្នាំ ១៩៩៩ ដល់ ២០០២

| | 1999 | | 2000 | | 2002 | |
|---|---|---|---|---|---|---|
| Characteristics | Frequency | % | Frequency | % | Frequency | % |
| Age | | | | | | |
| 14-19 years | 394 | 27.46 | 418 | 24.62 | 235 | 19.36 |
| 20-29 years | 973 | 67.8 | 1,177 | 69.32 | 890 | 73.31 |
| 30-39 years | 67 | 4.67 | 100 | 5.89 | 85 | 7 |
| 40-49 years | 1 | 0.07 | 3 | 0.18 | 4 | 0.33 |
| Schooling | | | | | | |
| <=4 years | 541 | 37.7 | 725 | 42.76 | 664 | 54.7 |
| 5-8 years | 662 | 46.13 | 809 | 47.64 | 477 | 39.29 |
| 9-12 years | 132 | 9.2 | 163 | 9.6 | 70 | 5.77 |
| >12 years | 100 | 6.97 | 0 | 0 | 3 | 0.25 |
| Married | 321 | 22.37 | 602 | 35.45 | 502 | 41.35 |
| Urban | - | - | - | - | - | - |

## លក្ខណៈប្រជាសាស្ត្រនៃមន្ត្រីប៉ូលីស
## ដែលចូលរួមក្នុងការសិក្សាស្រាវជ្រាវ ពីឆ្នាំ ១៩៩៩ ដល់ ២០០២

| | 1999 | | 2000 | | 2002 | |
|---|---|---|---|---|---|---|
| Characteristics | Frequency | % | Frequency | % | Frequency | % |
| Age | | | | | | |
| 14-19 years | 25 | 0.65 | 22 | 0.53 | 20 | 0.48 |
| 20-29 years | 912 | 23.74 | 738 | 17.85 | 575 | 13.87 |
| 30-39 years | 1,969 | 51.26 | 2,252 | 54.46 | 2,210 | 52.32 |
| 40-49 years | 809 | 21.06 | 935 | 22.61 | 1,096 | 26.44 |
| >=50 years | 126 | 3.28 | 188 | 4.55 | 244 | 5.89 |
| Schooling | | | | | | |
| <=4 years | 350 | 9.11 | 436 | 10.54 | 531 | 12.8 |
| 5-8 years | 1,987 | 51.73 | 2,456 | 59.4 | 2,278 | 54.9 |
| 9-12 years | 1,135 | 29.55 | 1,233 | 29.82 | 1,332 | 32.1 |
| >12 years | 369 | 9.61 | 10 | 0.24 | 8 | 0.19 |
| Married | 3,291 | 85.58 | 3,704 | 89.58 | 3,835 | 92.43 |
| Urban | - | - | - | - | - | - |

## អត្រាអាំស៊ីដង់ក្នុងចំណោមប្រជាជនគោលដៅពីឆ្នាំ ១៩៩៩-២០០២

| | 1999 | 2000 | 2002 | OR** | 95% CI | P-value |
|---|---|---|---|---|---|---|
| ស្ត្រីមានផ្ទៃពោះ | 0.72%* | 1.11%* | 0.59%* | 0.96 | 0.79-1.17 | 0.69 |
| ស្ត្រីរកស៊ីផ្លូវភេទផ្ទាល់ | 13.90% | 9.02% | 6.45% | 0.79 | 0.69-0.90 | 0.0003 |
| ស្ត្រីរកស៊ីផ្លូវភេទមិនផ្ទាល់ | 5.08% | 5.08% | 2.87% | 0.82 | 0.66-1.03 | 0.09 |
| ប៉ូលីស | 1.74%* | 1.30%* | 0.26%* | 0.64 | 0.48-0.84 | 0.001 |

* Incidence adjusted for the provincial population size

** odds ratio adjusted for age, marital status, location, school and province

## អត្រាអាំងស៊ីដង់ក្នុងចំណោមស្ត្រីមានផ្ទៃពោះនៅទីរួមខេត្ត និង ស្រុកក្រៅពីទីរួមខេត្ត ពីឆ្នាំ ១៩៩៩ ដល់ ២០០២

| | 1999 | 2000 | 2002 | OR** | 95% CI | P-value |
|---|---|---|---|---|---|---|
| ទីរួមខេត្ត | 1.00%* | 0.74%* | 0.24%* | 0.82 | 0.64-1.05 | 0.13 |
| ស្រុកក្រៅពីទីរួមខេត្ត | 0.11%* | 0.23%* | 0.42%* | 1.27 | 0.89-1.77 | 0.17 |

* Incidence adjusted for the provincial population size

** odds ratio adjusted for age, marital status, school and province

## អត្រាអាំស៊ីដង់ក្នុងចំណោមប្រជាជនគោលដៅនៅកម្ពុជា
## ពីឆ្នាំ ១៩៩៩ ដល់ ២០០២




## អត្រាអាំងស៊ីដង់ក្នុងចំណោមស្ត្រីមានផ្ទៃពោះ
## នៅតាមតំបន់ផ្សេងៗក្នុងប្រទេសកម្ពុជា




| | Western | Eastern | Central |
|---|---|---|---|
| 1999 | 0.35% | 0.24% | 1.17% |
| 2000 | 0.74% | 0.80% | 1.30% |
| 2002 | 1.48% | 0.15% | 0.59% |

## អត្រាអាំងស៊ីដង់ក្នុងចំណោមស្ត្រីរកស៊ីផ្លូវភេទដោយផ្ទាល់ នៅតាមតំបន់ផ្សេងៗក្នុងប្រទេសកម្ពុជា




| | Western | Eastern | Central |
|---|---|---|---|
| 1999 | 10.02% | 13.58% | 24.88% |
| 2000 | 9.30% | 4.21% | 11.06% |
| 2002 | 9.69% | 5.28% | 3.58% |

## អត្រាអាំងស៊ីដង់ក្នុងចំណោមស្ត្រីរកស៊ីផ្លូវភេទដោយមិនផ្ទាល់ នៅតាមតំបន់ផ្សេងៗក្នុងប្រទេសកម្ពុជា




| | Western | Eastern | Central |
|---|---|---|---|
| 1999 | 9.28% | 1.06% | 3.61% |
| 2000 | 2.87% | 1.35% | 6.89% |
| 2002 | 4.93% | 1.06% | 2.22% |

## អត្រាអាំងស៊ីដង់ក្នុងចំណោមប៉ូលិស
## នៅតាមតំបន់ផ្សេងៗក្នុងប្រទេសកម្ពុជា




| | Western | Eastern | Central |
|---|---|---|---|
| 1999 | 3.04% | 0.70% | 2.06% |
| 2000 | 0.80% | 0.35% | 2.37% |
| 2002 | 0.20% | 0.61% | 0.00% |

# ការពិភាក្សា

## សង្ខេបរបកគំឃើញ

- នេះគឺជាការប្រើប្រាស់បច្ចេកទេស BED-CEIA សំរាប់ប៉ាន់ស្មានអត្រាអាំងស៊ីដង់ក្នុងចំណោមប្រជាជនគោលដៅរបស់កម្មវិធីអង្កេតតាមដានមេរោគអេដស៏លើកទី១ហើយនៅលើពិភពលោកជាទូទៅ ហើយ ជាពិសេសនៅក្នុងប្រទេសកម្ពុជា។
- លទ្ធផលនៃកាសិក្សាស្រាវជ្រាវបញ្ជាក់អោយឃើញថា អត្រាអាំងស៊ីដង់ធ្លាក់ចុះក្នុងចំណោមប្រជាជនគោលដៅបីក្រុម : ស្ត្រីរកស៊ីផ្លូវភេទដោយផ្ទាល់ ស្ត្រីរកស៊ីផ្លូវភេទដោយមិនផ្ទាល់ និងក្រុមប៉ូលីស។ ក្រុមស្ត្រីមានផ្ទៃពោះ គឺជាក្រុមប្រជាជនតែមួយគត់ដែលអត្រាអាំងស៊ីដង់មិនទាន់មានការធ្លាក់ចុះនៅឡើយ។

## ភាពស៊ីគ្នា

- ការធ្លាក់ចុះនៃអត្រាអាំងស៊ីដង់ក្នុងចំណោមប្រជាជនគោលដៅទាំងបីក្រុម អាចឆ្លុះបញ្ចាំងពីប្រសិទ្ធិភាពនៃកម្មវិធីបង្ការការឆ្លងមេរោគអេដស៏នៅកម្ពុជា
- នេះមិនមែនជារឿងមួយប្លែកពីការរំពឹងទុកនោះទេដែលថាកម្មវិធីបង្ការការឆ្លងមេរោគអេដស៏មានឥទិពលតិចតួចលើការកាត់បន្ថយការចំលងមេរោគអេដស៏ ពីអ្នកដែលបានឆ្លងមេរោគហើយនោះ ទៅដល់ដៃគូរួមភេទនិងភរិយារបស់គាត់ ពីព្រោះការធ្វើតេស្តឈាមនិងការផ្តល់ប្រឹក្សានៅមិនទាន់មានគ្រប់គ្រាន់នៅក្នុងប្រទេសកម្ពុជា។ ទន្ទឹមនឹងនោះការប្រើប្រាស់ស្រោមអនាម័យជាមួយភរិយា រឺ សង្សារនៅមានកំរិតទាប។

## តេស្ត BED-CEIA គឺជាតេស្តមួយសមស្របសំរាប់ប្រទេសកម្ពុជា

- តេស្តធ្វើឡើងនៅលើសំនាកដែលមានផ្ទុកមេរោគអេដស៍ ដែលរកឃើញស្រាប់ដោយកម្មវិធីអង្កេតតាមដានហើយតែប៉ុណ្ណោះ
- តេស្ត **BED-CEIA** នេះធ្វើឡើងដោយប្រើល្បាយ ១:១០០ ដែលមានលក្ខណៈងាយស្រួលជាងតេស្ត **sensitive-less sensitive EIA** សំរាប់កំនត់រកអ្នកឆ្លងថ្មី ដែលទាមទារអោយប្រើល្បាយ ១:២០.០០០
- តេស្តនេះអាចប្រើប្រាស់បាននៅលើមេរោគអេដស៍បីប្រភេទ **B, D** រឺ **E**

## ការធ្វើតេស្ត BED-CEIA

- បួនភាគរយនៃអ្នកជំងឺអេដស៍ បើក្នុងដំណាក់កាលចុងក្រោយអាចមានកំរិតអង់ទីករទាប ហើយអាចធ្វើអោយតេស្ត BED-CEIA យល់ច្រឡំថាជាអ្នកទើបឆ្លងថ្មី ។ ប៉ុន្តែករណីនេះ ប្រហែលជាមិនងាយនឹងកើតឡើងនៅក្នុងការសិក្សារបស់យើងទេ ។
- លទ្ធផលតេស្តខុសឆ្គងក៏អាចកើតមានផងដែរ ក្នុងករណីដែលអ្នកជំងឺអេដស៍ដែលប្រើថ្នាំពន្យាជីវិត ព្រោះការប្រើថ្នាំនេះអាចបណ្តាលអោយមានការធ្លាក់ចុះនូវអង់ទីករ ។ ប៉ុន្តែករណីនេះ ប្រហែលជាមិនងាយនឹងកើតឡើងនៅក្នុងការសិក្សារបស់យើងទេ ។
- លទ្ធផលខុសឆ្គងក៏អាចមានតាមរយៈកំហុសនៃចំនុចកាត់នៃដង់ស៊ីតេអុបទិកផងដែរ ប៉ុន្តែកំហុសនេះនឹងមិនប៉ះពាល់ដល់ការសិក្សាពីការវិវត្តនៃអត្រាអាំងស៊ីដង់ទេ ។

## ធនធានមនុស្ស និង សម្ភារ

- ការគ្របដណ្តប់ដ៏ទូលំទូលាយនៃកម្មវិធីអង្កេតតាមដានមេរោគអេដស៍នៅកម្ពុជារួមផ្សំទាំងការផ្លាស់ប្តូរមន្ត្រីទទួលខុសត្រូវការងារផងនោះ បានធ្វើអោយការថែរក្សានូវនិតិវិធីប្រតិបត្តិស្តង់ដារអោយបានស៊ីគ្នាអាចជួបការលំបាក

## ការជ្រើសរើសអ្នកចូលរួម

- ស្រីមានផ្ទៃពោះដែលចូលរួមក្នុងកម្មវិធីអង្កេតតាមដានមេរោគអេដស៍ មិនអាចតំណាងអោយស្ត្រីមានផ្ទៃពោះទូទៅក្នុងប្រទេសកម្ពុជាបានទេ។

- ដោយហេតុថាមានការបង្កើនចំនួនស្ត្រីមានផ្ទៃពោះក្មេង នៅឆ្នាំ២០០២ អត្រាអាំងស៊ីដង់របស់ស្ត្រីមានផ្ទៃពោះនៅឆ្នាំ២០០២ អាចកើនខ្ពស់ជាងអត្រាអាំងស៊ីដង់ ដែលប្រសិនជាគេធ្វើការជ្រើសរើសស្ត្រីមានផ្ទៃពោះដូចកាលឆ្នាំ១៩៩៩ និង២០០០ ពីព្រោះស្ត្រីមានផ្ទៃពោះក្មេងមានប្រូបាប៊ីលីតេក្នុងការឆ្លងមេរោគអេដស៍ថ្មីៗ ខ្ពស់ជាងស្ត្រីមានផ្ទៃពោះចាស់ៗ។ ចំនុចពិភាក្សាដូចគ្នានេះ ក៏អាចលើកឡើងចំពោះ ករណី ស្ត្រីរកស៊ីផ្លូវភេទដោយផ្ទាល់ និង មិនផ្ទាល់ ។

## ការប្រកែកមិនចូលរួមកម្មវិធីអង្កេតតាមដាន

- អត្រានៃការប្រកែកខ្ពស់បំផុតគឺនៅឆ្នាំ១៩៩៩ ហើយយើងមិនបានដឹងអំពីលក្ខណៈប្រជាសាស្ត្រ និង ការប្រព្រឹត្តនៃអ្នកដែលប្រកែកនោះទេ

- បើសិនជាអ្នកដែលប្រកែកនោះ មានការប្រព្រឹត្តប្រឈមមុខនឹងគ្រោះថ្នាក់នៃការឆ្លងមេរោគអេដស៍ជាងអ្នកដែលចូលរួម ពេលនោះលទ្ធផលរបស់យើងអាចមានការផាស់ប្តូរ ហើយការវិវត្តន៍នៃអត្រាអាំងស៊ីដង់ក៏អាចមានការផ្លាស់ប្តូរដែរ ។

## តេស្តវិជ្ជមានដែលខុស_តេស្តអវិជ្ជមានដែលខុស

- យើងបានរកឃើញថា ក្នុងចំណោមសំនាកដែលយើងបានដឹកជញ្ជូនមក UCLA សំនាកមួយចំនួនជាសំនាកវិជ្ជមានដែលខុស ហើយសំនាកមួយចំនួនពុំមានសេរ៉ូមគ្រប់គ្រាន់សំរាប់ធ្វើតេស្ត

- យើងបានដឹងអំពីអត្រា តេស្តវិជ្ជមានដែលខុស ហេតុនេះជាការមួយសំខាន់ណាស់ដែលយើងត្រូវសិក្សាមើលថាអត្រាតេស្តអវិជ្ជមានដែលខុសមានដល់កំរិតណា

## ការសន្មតិ

- តាមរយៈលទ្ធផលដែលយើងបង្ហាញនេះគឺមានការសន្មតិថា គ្មានសំណាកអវិជ្ជមានដែលខុសទេ ។ ប៉ុន្តែបើការសន្មតិនេះមិនត្រឹមត្រូវទៅវិញនោះអត្រាអាំងស៊ីដង់ដែលយើងរកឃើញនេះអាចនៅទាបនៅឡើយ ។ ប៉ុន្តែគេមិនអាចប្រមើលមើលថាតើការវិវត្តន៍អត្រាអាំងស៊ីដង់ គឺនឹងដូចការវិវត្តន៍ដែលបានឃើញខាងដើមនេះបានទេ ។

- ដោយហេតុយើងកំនត់ថាតេស្ត BED-CEIA អាចរកឃើញអ្នកឆ្លងថ្មីក្នុងរយៈពេល១៦៨ ថ្ងៃ លក្ខខ័ណ្ឌសំរាប់គណនាអាំងស៊ីដង់ដែលថា ” ចំនួនប្រជាជនថេរ ” គឺអាចគោរពបាន

## ការសន្មតិ

- ការប៉ាន់ស្មានអត្រាអាំងស៊ីដង់ សំអាងលើ ភាពត្រឹមត្រូវនៃរយៈពេលឆ្លងថ្មី ។ ហេតុនេះការបន្តវាយតំលៃលើសុពលភាពរបស់តេស្ត BED-CEIA មានសារៈសំខាន់ណាស់ក្នុងការវាយតំលៃ លើលទ្ធផលនៃការសិក្សាស្រាវជ្រាវនេះ ។ ក៏ប៉ុន្តែ លំអៀងក្នុងការប៉ាន់ស្មានរយៈពេលនេះ នឹងមិនមានការប៉ះពាល់លើការវិភាគលើការប្រែប្រួលអាំងស៊ីដង់ ពី ឆ្នាំ ១៩៩៩ ដល់ ២០០២ ទេ ។
- ការសន្មតិមួយទៀតគឺអត្រានៃសំនាកវិជ្ជមានដែលខុស គឺមានលក្ខណៈដូចគ្នារវាងសំនាកដែលបានយកមកធ្វើតេស្តនៅ UCLA និង សំនាកដែលមិនបានយកមកធ្វើតេស្ត ។ ប៉ុន្តែតាមរយៈ ការវិភាគ Sensitivity យើងឃើញថាការវិវតនៃអត្រាអាំងស៊ីដង់ ពុំមានការផ្លាស់ប្តូរទេ ។

## ការវិភាគស្ថាទីស្ទីក

- ដោយសារក្រុមគោលដៅខ្លះត្រូវបានជ្រើសរើសជាចង្កោម តែក្នុងការវិភាគស្ថាទីស្ទិកយើងប្រើវិធី វិភាគសំរាប់ការជ្រើសរើសចាប់ឆ្នោតសាមញ្ញ (SRS) ហេតុនេះយើងអាចទទួលបាននូវការប្រែប្រួលទាបជាង **(Smaller Variance)**

- ចំនួនអ្នកចូលរួមសំរាប់កម្មវិធីអង្កេតតាមដានដែលមជ្ឈមណ្ឌលបានគណនាគឺសំរាប់តាមដានមើលការប្រែប្រួល ប្រេវ៉ាឡង់ ដែលខ្ពស់ជាងអាំងស៊ីដង់ ហេតុនេះការសិក្សាយើងនេះដែលប្រើចំនួនអ្នកចូលរួមដែលគណនាជាស្រេចនោះអាចមានអំណាចទាប **(Low power)**

## ការប្រើប្រាស់លទ្ធផល និង អនុសាសន៍

- ប្រទេសកម្ពុជាបានបន្ថយនូវការចំលងមេរោគអេដស៏ក្នុងចំណោមប្រជាជនដែលប្រឈមមុខខ្ពស់នឹងគ្រោះថ្នាក់ ប៉ុន្តែកំពុងតែប្រឈមមុខនឹងការចំលងមេរោគអេដស៏ ក្នុងចំណោមប្រជាជនទូទៅ ។
- អេពីដេមីនៅតែបន្តរាលដាលក្នុងចំណោមប្រជាជនទូទៅ បើសិនជាគ្មានវិធានការណ៏មានប្រសិទ្ធិភាពក្នុងការបង្ការការចំលងនេះទេ ។
- ការសិក្សាថ្មីៗទៀតគួរតែផ្តោតទៅលើយុទ្ធសាស្រ្តក្នុងការការពារ ភរិយា និង សង្សារ ។ កម្មវិធីបង្ការចំលងមេរោគអេដស៏ក្នុងចំណោមប្រជាជននេះត្រូវតែខំប្រឹងប្រែងថែមទៀត
- ដោយសារក្រុមស្រ្តីរកស៊ីផ្លូវភេទនៅកម្ពុជាមានអត្រាអាំងស៊ីដង់ខ្ពស់ ក្រុមប្រជាជននេះមានលក្ខណៈសមស្របសំរាប់ចូលរួមក្នុងការសិក្សាស្រាវជ្រាវវ៉ាក់សាំង ។

## ការប្រើប្រាស់លទ្ធផល និង អនុសាសន៍

- គេគួរតែរៀបចំបង្កើតនិតិវិធីប្រតិបត្តិស្តង់ដារមួយ សំរាប់កម្មវិធីអង្កេតតាមដានរកមេរោគអេដស៍នៅកម្ពុជា
- គួរបង្កើតយន្តការនៃការត្រួតពិនិត្យ និងធានាអោយបាននូវគុណភាពនៃការធ្វើតេស្តសំរាប់កម្មវិធីអង្កេតតាមដានមេរោគអេដស៍នៅកម្ពុជា
- បញ្ចូលទៅក្នុងកម្មវិធីអង្កេតតាមដានរកមេរោគអេដស៍ នូវយុទ្ធសាស្ត្រធ្វើតេស្ត ដែលអាចកាត់បន្ថយការប្រកែកមិនចូលរួម និងយុទ្ធសាស្ត្រនៃការ ធ្វើតេស្តដែលអាច បែងចែកអ្នកឆ្លងថ្មីពីអ្នកឆ្លងយូរមកហើយ (ដូចជា **BED-CEIA** ជាដើម)

## សេចក្តីសន្និដ្ឋាន

ការរាលដាលមេរេគអេដស៍នៅកម្ពុជា បានឈានដល់ដំណាក់កាលមានលំនឹងហើយ ។ អត្រាអាំងស៊ីដង់ក្នុងចំណោមប្រជាជនគោលដៅបីក្រុម (ស្ត្រីរកស៊ីផ្លូវភេទដោយផ្ទាល់ ស្ត្រីរកស៊ីផ្លូវភេទ ដោយមិនផ្ទាល់ និងប៉ូលីស) បានធ្លាក់ចុះចន្លោះពីឆ្នាំ ១៩៩៩ ដល់ ២០០២ ។ ប៉ុន្តែការរាលដាល មេរោគអេដស៍មិនទាន់មានស្រាកស្រាន្តនៅឡើយទេ នៅក្នុងចំណោមស្ត្រីមានផ្ទៃពោះ ។ ការធ្លាក់ចុះនៃអត្រាប្រេវ៉ាឡង់មេរោគអេដស៍ គឺរួមចំណែកមួយផ្នែកដោយសារ ការធ្លាក់ចុះនូវអត្រាអាំងស៊ីដង់ ។